ព្រះរាជាណាចក្រកម្ពុជា -149-

ជាតិ សាសនា ព្រះមហាក្សត្រ

-----------------

តុលាការកំពូល
----------

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៥៥

ចុះថ្ងៃទី២៣ខែសីហា ឆ្នាំ២០០១

សាលដីកា

លេខ : ២៧

ចុះថ្ងៃទី២០ខែមិនា ឆ្នាំ២០០២

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

---------

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២០ ខែមិនា ឆ្នាំ២០០២

ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ :

១ - ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន

២ - លោក ឈឹម គឹមផល ចៅក្រម

៣ - លោក ស៊ិន ឌឹម ចៅក្រម

៤ - លោក ឃំ សួខឿន ចៅក្រមរបាយការណ៍

៥ - លោក ប្រាក់ គឹមសាន ចៅក្រម

ក្រឡាបញ្ជី

លោក សាន សុផាត

តំណាងមហាអយ្យការ

លោក ឃួន ចាន់ថា ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសារទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ១៧៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ១៥៥ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០១របស់តុលាការកំពូល ។

ពីបទៈ បង្ករបួស[illegible] និង ជេរប្រមាថទៅវិញទៅមក ប្រព្រឹត្តនៅភូមិតាខ្មៅ ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៧-៨-១៩៩៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង អោយផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៤១-៦៣នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចុះថ្ងៃទី១០-៩-១៩៩២ ។

១ - ជនជាប់ចោទឈ្មោះទេព គឹមស្រ៊ុន "ជាម្ចាស់បណ្តឹងសារទុក្ខ" ភេទស្រី អាយុ២៣ឆ្នាំ ជាតិខ្មែរ កើតនៅស្រុកមុខកំពូល ខេត្តកណ្តាល របររកស៊ីលក់ខោអាវ ទីលំនៅបច្ចុប្បន្នភូមិព្រែកសំរោង ឃុំ-តាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល ឪពុកឈ្មោះប៊ូ លាងទេព "ស" ម្តាយឈ្មោះហ៊ុន គឹមទៀង ប្តីឈ្មោះនិន សោភណ្ឌ កូនគ្មាន ។ ក្រៅឃុំ ។ មេធាវី គ្មាន ។

២ - ជនជាប់ចោទឈ្មោះម៉ាន់ គឹមស្រ៊ុន ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ កើតនៅស្រុកគៀនស្វាយ ខេត្តកណ្តាល របររកស៊ីលក់ខោអាវ ទីលំនៅបច្ចុប្បន្នភូមិចំពុះក្អែក ឃុំ-ស្រុកគៀនស្វាយ ខេត្តកណ្តាល ឪពុកឈ្មោះម៉ាន់ ណៅ "ស" ម្តាយឈ្មោះគីម ស្រី "ស" នៅលីវ ។ ក្រៅឃុំ ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះតិច ទីមស្រ៊ី "ជាចុងបណ្តឹងសារទុក្ខ" ភេទស្រី អាយុ៦៣ឆ្នាំ ជាតិខ្មែរ របររកស៊ីចាក់ដេរ ទីលំនៅបច្ចុប្បន្នភូមិចំពុះក្អែក ឃុំព្រែកថ្មី ស្រុកគៀនស្វាយ ខេត្តកណ្តាល ។

- តាមពាក្យប្តឹងចុះថ្ងៃទី១៨ - ៨ - ១៩៩៨របស់ឈ្មោះតិច គីមស្រ៊ី ប្តឹងពីបទបង្កខូចខាតរូប មកលើខ្លួន ដោយសំអាងហេតុថា ៖ កាលពីថ្ងៃទី១៧ - ៨ - ១៩៩៨ វេលាម៉ោង១០ព្រឹកឈ្មោះហេង គីមស្រ៊ុន ព្រួញយកកៅអីមានជើងដែកនឹងវាយមកលើខ្លួន បណ្តាលអោយត្រូវមុខមានស្នាមហូរឈាមទៀងភ្នែក ត្រូវដេរ៥បណ្តាល អោយដាក់ភ្ជួនដេរ ។

- តាមពាក្យប្តឹងចុះថ្ងៃទី១៧ - ៨ -៩៨របស់ឈ្មោះហេង គីមស្រ៊ុន ប្តឹងពីបទបង្ករបួសស្នាមលើខ្លួន ដោយសំអាងហេតុថា ៖ កាលពីថ្ងៃទី១៧ - ៨ - ៩៨ វេលាម៉ោង១០ព្រឹកខ្លួនកំពុងអង្គុយលក់ឥវ៉ាន់ ពេលនោះខ្លួន ខកខានបង់ភ្លួត គឺសុំអោយអ្នកលក់ក្បែរនោះទីឥវ៉ាន់ខិតបន្តិច ព្រោះខ្លួនខ្លាចភ្លួតលើឥវ៉ាន់គេ ប៉ុន្តែអ្នកទាំង២នាក់ពុំព្រមស្តាប់ ហើយបែរជាត្រឡប់គ្នាមកវាយខ្លួនទាំងម្តាយ ទាំងកូន ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ អម តុលាការខេត្តកណ្តាលថា ៖

១ - ចោទប្រកាន់លើឈ្មោះហេង គីមស្រ៊ុន ពីបទបង្ករបួសស្នាមដោយចេតនាលើ យាយ គីមស្រ៊ី ។

២ - ចោទប្រកាន់លើឈ្មោះហេង គីមស្រ៊ុន និង ម៉ាន់ គីមស្រ៊ិន ពីបទ៖ ជេរប្រមាថ គ្នាទៅវិញទៅមក ប្រព្រឹត្តនៅភូមិតាខ្មៅ ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៧ - ៨ - ៩៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង អោយផ្តន្ទាទោសតាមមាត្រា៤១ - ៦៣នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១០៧ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩របស់តុលាការខេត្ត កណ្តាលដែលបានសំរេច ៖

១ - បដិសេធចោលជាអសារបង់នូវសំណូមពររបស់ជនជាប់ចោទឈ្មោះហេង គីមស្រ៊ុន ហៅដារ៉ាដោយផ្ទុយនឹងច្បាប់ ដោយហេតុពុំទៀងមានធាតុផ្សំបទល្មើសគ្រប់គ្រាន់តាមផ្លូវច្បាប់ហើយ ។

២ - ផ្តន្ទាទោសឈ្មោះហេង គីមស្រ៊ុនហៅដារ៉ា ដាក់ពន្ធនាគារកំណត់១ឆ្នាំ ប៉ុន្តែទោស នេះត្រូវព្យួរ និង បន្ថែមរយៈពេលសាកល្បង៥ឆ្នាំតាមកំណត់ច្បាប់ ពីបទ៖ បង្ករបួសស្នាមដោយចេតនាលើនាង គីមស្រ៊ី និង ពីបទ៖ ជេរប្រមាថលើនាងម៉ាន់ គីមស្រ៊ិន ប្រព្រឹត្តនៅភូមិតាខ្មៅ ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៧ -៨ - ៩៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា៤១ ៦៣ - ៥៨ - ៧០នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣ - ផ្តន្ទាទោសនាងម៉ាន់ គីមស្រ៊ិន ដាក់ពន្ធនាគារកំណត់៣ខែ ប៉ុន្តែទោសនេះត្រូវ ព្យួររយៈពេលសាកល្បង៥ឆ្នាំតាមកំណត់ច្បាប់ ពីបទ៖ ជេរប្រមាថលើនាង គីមស្រ៊ុន ប្រព្រឹត្តនៅផ្សារតាខ្មៅ កាលពីថ្ងៃទី១៧ - ៨ - ១៩៩៨បទល្មើសព្រហ្មទណ្ឌដែលមានចែង និង អោយផ្តន្ទាទោសតាមមាត្រា៦៣ -៦៨ - ៧០នៃ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤ - បង្គាប់អោយជនជាប់ចោទឈ្មោះហេង គីមស្រ៊ុនហៅដារ៉ាបង់ជំងឺចិត្តក្នុងការព្យាបាល ទៅអោយជនរងគ្រោះឈ្មោះគីមស្រ៊ីចំនួន១ ០០០ ០០០រៀល សុំលើសពីនេះលើកចោល ។

បើគ្មានប្រាក់សងត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុង បើនឹងទើងត្រូវដាក់គុកបង្ខំ រូបកាយចំនួន២ឆ្នាំតាមបញ្ញត្តិមាត្រា៧នៃច្បាប់ស្តីពីការដាក់គុកបង្ខំរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៥ - វត្ថុតាង មានកៅអីដែកបត់ជើងមួយត្រូវបំផ្លាញចោល ។

សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និង ជនរងគ្រោះ

បើកសិទ្ធិប្តឹងឧទ្ធរណ៍រយៈពេល២ខែ ដោយគិតចាប់ពីថ្ងៃនេះតទៅ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៣ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ១៩៩៩របស់ឈ្មោះតិច គឹមស្រី ដែលប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ០៧ "វ" ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩របស់តុលាការខេត្តកណ្តាល ត្រង់ចំណុចស្តីពីសំណងជំងឺចិត្ត និង ថ្លៃថ្នាំពេទ្យព្យាបាល ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៦ ចុះថ្ងៃទី២២ ខែមិនា ឆ្នាំ១៩៩៩របស់ឈ្មោះហេង គឹមស្រ៊ុន ដែលប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ០៧ "វ" ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩របស់តុលាការខេត្ត-កណ្តាលលើសេចក្តីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម តុលាការឧទ្ធរណ៍ថា : សូមរក្សាសាលក្រមព្រហ្មទណ្ឌលេខ០៧ "វ" ចុះថ្ងៃទី២៩-០១-៩៩របស់តុលាការខេត្តកណ្តាលទុកជាបានការ តែបដិសេធចំណុចទី១ បន្ថែមបន្ថយទោសតាមមាត្រា៦៨ច្បាប់ព្រហ្មទណ្ឌអន្តរកាល និង ដាក់ទោសអោយបានត្រឹមត្រូវ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌកំបាំងមុខលេខ២៣ ចុះថ្ងៃទី២១-១-២០០០របស់សាលាឧទ្ធរណ៍ ដែលបានសំរេច : ១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៣-៣-៩៩របស់ឈ្មោះហេង គឹមស្រ៊ុន និង បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៩-៣-៩៩របស់ឈ្មោះតិច គឹមស្រីទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹង-គតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ០៧ "វ" ចុះថ្ងៃទី២៩-០១-៩៩របស់តុលាការខេត្តកណ្តាលទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ-ម៉ាន់ គឹមស្រ៊ុន ដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីជនជាប់ចោទ កំបាំងមុខជនជាប់ចោទឈ្មោះហេង គឹមស្រ៊ុន បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងទាស់លេខ០៧ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០របស់ឈ្មោះហេង គឹមស្រ៊ុន ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌកំបាំងមុខលេខ២៣ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០០របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០១របស់សាលាឧទ្ធរណ៍ ដែលបានសំរេច : ១-ទទួលបណ្តឹងទាស់ចុះថ្ងៃទី១៦-០២-២០០០របស់ឈ្មោះហេង គឹមស្រ៊ុនទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាកំបាំងមុខលេខ២៣ ចុះថ្ងៃទី២១-០១-២០០០របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ-ហេង គឹមស្រ៊ុន និង ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះម៉ាន់ គឹមស្រ៊ន បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ១២ ចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០១របស់ឈ្មោះហេង គឹមស្រ៊ុន ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០០របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណា ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០១របស់ឈ្មោះទេង គីមស្រ៊ុន " ជាម្ចាស់បណ្តឹងសាទុក្ខ " ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានឃើញសារណាឆ្លើយតបចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០១របស់ឈ្មោះតិច គីមស្រ៊ី " ជាចុងបណ្តឹងសាទុក្ខ " ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់អំណានសារតាជាតិរបស់ឈ្មោះទេង គីមស្រ៊ុន " ជាម្ចាស់បណ្តឹងសាទុក្ខ " នៅពេលជំនុំជំរះ ។

- បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម តុលាការកំពូលថា ៖ រឿងនេះ តុលាការថ្នាក់ក្រោមពុំបានពិចារណាលើសាក្សីដាក់បន្ទុករបស់ជនល្មើសទេ ដូច្នេះសូមតុលាការទុកជាមោឃៈ សាលដីកាសាលាឧទ្ធរណ៍ ។

- បានស្តាប់អំណានសារណារបស់ឈ្មោះទេង គីមស្រ៊ុន " ជាម្ចាស់បណ្តឹងសាទុក្ខ " នៅពេល - ជំនុំជំរះ ។

- បានស្តាប់ចម្លើយអះអាងរបស់ឈ្មោះតិច គីមស្រ៊ី " ជាចុងបណ្តឹងសាទុក្ខ " នៅពេលជំនុំជំរះ ថា ៖ ការលើកឡើងក្នុងសារណារបស់ឈ្មោះទេង គីមស្រ៊ុនមិនពិតទេ គ្រប់តុលាការជាន់នេះមិនដែលបាន ចូលរួមតទល់គ្នាទេ សូមតុលាការជួយរកយុត្តិធម៌ ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមនាពេលសវនាការរបស់តំណាងមហាអយ្យការ អម តុលាការ កំពូលថា ៖ សូមរក្សាបទចោទនៅដដែល ។

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណារបស់ជនជាប់ចោទ និងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ១២ ចុះថ្ងៃទី២០ - ៣ - ២០០១របស់ឈ្មោះទេង គីមស្រ៊ុន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការ ចាត់តាំង និង សកម្មភាពរបស់តុលាការជំរះក្តី ។

- យល់ឃើញថា ការលើកឡើងរបស់ឈ្មោះទេង គីមស្រ៊ុនក្នុងសារណាចុះថ្ងៃទី២៥ ខែ តុលា ឆ្នាំ២០០១ថា ៖ ទំនាស់រវាងខ្លួន និង ភាគីតិច គីមស្រ៊ី កើតឡើងដោយគាងយាម គីមស្រ៊ី និង ម៉ាន់- គីមស្រ៊ុនបង្កឡើងមុន ចំណែកខ្លួនគ្រាន់តែជាអ្នកការពារខ្លួនរាល់អំពើបំពានលើរូបកាយខ្លួនដែលមានរបួស ដូចគ្នា នោះគឺជាការពុំត្រឹមត្រូវឡើយពីព្រោះថា ៖

. -- មានភស្តុតាង និង ពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះទេង គីមស្រ៊ុន ដែលបានយកកាំបិតដែកពន្លាយលើឈ្មោះគីម ស្រ៊ីបណ្តាលអោយមានរបួសធ្ងន់ព្រមទាំងជេរប្រមាថគ្នាទៅវិញទៅ មកជាមួយឈ្មោះម៉ាន់ គីមស្រ៊ុន ប្រព្រឹត្តនៅផ្សារតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី១៣ - ៨ - ១៩៩៨ [illegible]

មែន បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៥១និង៦៣នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-មានភស្តុតាងបញ្ជាក់ថា ឈ្មោះម៉ាន់ គឹមស្រ៊ុនពិតជាបានជេរប្រមាថគ្នាទៅវិញទៅមកជាមួយឈ្មោះហេង គឹមស្រ៊ុននៅផ្សារតាខ្មៅ ខេត្តកណ្តាលកាលពីថ្ងៃទី១៧-៨-៩៨ ប្រាកដមែន ។

-យល់ឃើញថា ជនជាប់ចោទបានធ្វើសារណាជូនមកតុលាការកំពូលហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០១របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ ៖

១-ទទួលបណ្តឹងសាទុក្ខលេខ១១២ ចុះថ្ងៃទី២០-៣-២០០១របស់ឈ្មោះហេង គឹមស្រ៊ុនទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០១របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០០២ ។